**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ**
**អព្យាក្រឹត និង វឌ្ឍនភាពសង្គម**

## សូមគោរពជូន
## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## ប្រធានគណបក្សប្រជាជនកម្ពុជា និងជានាយករដ្ឋមន្ត្រី
## នៃព្រះរាជាណាចក្រកម្ពុជា

ក្នុងឱកាសដ៏មហានក្ខត្តប្ញក្សឧត្តុង្គឧត្តមប្រពៃថ្លៃថ្លាបំផុត ដែលសម្តេចត្រូវបានអង្គសន្និបាតគណៈកម្មាធិការកណ្តាលលើកទី៣៨ អាណត្តិទី៥ នៃគណបក្សប្រជាជនកម្ពុជា បោះឆ្នោតជ្រើសតាំងជា **ប្រធានគណបក្ស** ខ្ញុំបាទសូមសម្តែងនូវសេចក្តីសោមនស្សរីករាយឥតឧបមា និងអំណរសាទរយ៉ាងជ្រាលជ្រៅកក់ក្តៅជាទីបំផុត ជូនចំពោះ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានគណបក្សប្រជាជនកម្ពុជា និងជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

ការបោះឆ្នោតប្រគល់តួនាទីដឹកនាំដ៏ខ្ពង់ខ្ពស់បំផុត ជូនសម្តេចអគ្គមហាសេនាបតីតេជោ នាពេលនោះ គឺជាសក្ខីភាពឆ្លុះបញ្ចាំងឲ្យឃើញនូវសមត្ថភាពការងារដ៏ឧត្តុងឧត្តម ការខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តប្រាជ្ញាស្មារតីពុះពារជំនះរាល់ឧបសគ្គនានា ដោយភាពអង់អាចក្លាហាន ប្រកបដោយបញ្ញាញាណគតិបណ្ឌិតដ៏ឈ្លាសវៃ បទពិសោធន៍ដឹកនាំដ៏ឆ្នើម ជាមួយនឹងសមិទ្ធផលការងារជាប្រវត្តិសាស្ត្រយ៉ាងច្រើនឥតគណនា ការសម្រេចបាននូវសុខសន្តិភាព ស្ថិរភាពនយោបាយ ការការពារបាននូវឯករាជ្យជាតិ និងបូរណភាពទឹកដី រហូតធ្វើឲ្យព្រះរាជាណាចក្រកម្ពុជាទទួលបាននូវកិត្យានុភាពដ៏ត្រចះត្រចង់ ទាំងក្នុងតំបន់ និងនៅលើឆាកអន្តរជាតិ។

ជាថ្មីម្តងទៀត ក្នុងឱកាសដ៏វិសេសវិសាលបំផុតនេះ ខ្ញុំបាទសូមគោរពជូនពរបវរមហាប្រសើរថ្លៃថ្លាបំផុតជូន**សម្តេចអគ្គមហាសេនាបតីតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត** បុត្រា-បុត្រី ចៅប្រុស-ចៅស្រី ជាទីស្រឡាញ់របស់សម្តេច សូមមានសុខភាពល្អបរិបូណ៌ ពលានុភាពខ្លាំងក្លា ប្រាជ្ញាវាងវៃ ព្រមទាំងទទួលបានជោគជ័យ និងសមិទ្ធផលជាប្រវត្តិសាស្ត្រកាន់តែត្រចះត្រចង់ ធំធេងថែមទៀត ក្នុងការបន្តដឹកនាំគណបក្សប្រជាជនកម្ពុជា រាជរដ្ឋាភិបាលកម្ពុជាដ៏ឧត្តុង្គឧត្តម នាវាកម្ពុជា ប្រជាជាតិកម្ពុជាទាំងមូល ឆ្ពោះទៅកាន់ត្រើយសុភមង្គល និងការអភិវឌ្ឍលើគ្រប់វិស័យ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ និងស្មោះស្ម័គ្របំផុត ពីខ្ញុំបាទ

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៥

**សមាជិកគណៈកម្មាធិការកណ្តាល**

គង់ វិបុល